294



# ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៤៤

លេខ: ៦៩

ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៤ **តាងនាមប្រជារាស្ត្រខ្មែរ**

**<u>សាលដីកា</u>** **តុលាការកំពូល**

លេខ: ២៦៧ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤

ចុះថ្ងៃទី១៨ខែវិច្ឆិកាឆ្នាំ២០០៤ ដោយមានសមាសភាព ដូចតទៅ:

១- ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២- លោក ប្រាក់ គឹមសាន ជាចៅក្រម

៣- លោក ជីវ កេង ជាចៅក្រមរបាយការណ៍

៤- លោក សោម សិរីវឌ្ឍ ជាចៅក្រម

៥- លោក យស់ សូខឿន ជាចៅក្រម

ក្រឡាបញ្ជី

លោក **ទៅ សុវណ្ណ**

តំណាងមហាអយ្យការ

ឯកឧត្តម **ថុន ស៊ុនឡៃ** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១៤២(ង) ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ៧៧០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **តៅ ប៊ុនចាង** (ម្ចាស់បណ្តឹងសាទុក្ខ) អគ្គមេធាវីរាជរដ្ឋាភិបាល តំណាងឱ្យអាជ្ញាធរ ខេត្តកណ្តាល ។

ផ្ទេរសិទ្ធិអោយ លោក គង់ ចំរើន ។

ចុងចម្លើយឈ្មោះ **វ៉ង សារិន** អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរយោធា មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ២៤៤ "ឌុ" ផ្លូវលំ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ វ៉ង ស៊ីម ម្តាយឈ្មោះ ជុក អ៊ីម ប្រពន្ធឈ្មោះ ឈួន ម៉ាលីម មានកូន៦នាក់ ។

មានមេធាវីលោក សែម ចិន្តា ។

**<u>ចម្លងកម្មវត្ថុ</u>** : ប្តឹងសុំលុបចោលប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដី .

បានឃើញបណ្តឹងសាទុក្ខលេខ៣៧២ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះ គង់ ចំរើន

ប្តឹងមិនសុខចិត្តនឹងសាលដីកាវដ្តប្បវេណីលេខ ១៤២ "ង" ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៦៩ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩ របស់បណ្ឌិតកៅ ប៊ុនហុង ប្តឹងសុំលប់បណ្ណ័កម្មសិទ្ធិលេខ $G_2$ ០១១០ របស់លោក វ៉ង សារិន ដោយសំអាងហេតុថា នៅឆ្នាំ១៩៩២ រដ្ឋអំណាចខេត្តកណ្តាល បានប្រកាសរំលាយចោលបណ្ណ័សំគាល់សិទ្ធិរបស់លោក វ៉ង សារិន តាមស្មារតីសេចក្តីសំរេចលេខ ០២៥ សសរ ចុះថ្ងៃទី០៦ -៣-១៩៩២ ហើយបានយកដីធ្លីទាំងអស់ទៅចែកជូនប្រជាជនភូមិបោះអង្គាញ់វិញ ។ នៅឆ្នាំ១៩៩៦ លោកបានយកបណ្ណ័សំគាល់ សិទ្ធិនេះទៅប្តឹងតុលាការទាមទារដី ។តាមសាវតាដីនេះ ពីឆ្នាំ១៩៧៩ ដល់ ១៩៨៩ ប្រជាជនភូមិបោះអង្គាញ់ជាអ្នក កាន់កាប់នៅឆ្នាំ១៩៨៩ រដ្ឋអំណាចស្នើសុំពីប្រជាជនធ្វើមណ្ឌលគណៈបក្សប្រជាជន ហើយមណ្ឌលបក្ស រដ្ឋអំណាចស្រុក អំណោយអោយកម្មាភិបាលបុគ្គលិកមួយចំនួន ។ ការធ្វើអំណោយនេះធ្វើឱ្យប្រជាជនភូមិបោះអង្គាញ់ខឹង ដោយឃើញសកម្មភាពបែបនេះ ទើបគណៈកម្មាធិការប្រជាជនខេត្តកណ្តាលចេញសេចក្តីសំរេចលេខ ០២៥ សសរ សំរេច ប្រគល់ដីសល់ពីមណ្ឌលបក្ស និងដីនៅសល់ទុកជាប្រយោជន៍មណ្ឌលបក្សជូនទៅប្រជាជនវិញ ។ ជាក់ស្តែងដីលោក វ៉ង សារិន បានមកពីរដ្ឋអំណាចស្រុកកៀនស្វាយ ធ្វើជាអំណោយអោយលោក ជុំ សៀង និង ឯក សំអួន ហើយលោក ទាំងពីរបានលក់បន្តអោយលោក លី កុសល ហើយ លោក លី កុសល ចែកឱ្យលោក វ៉ង សារិន ហើយសុំកាន់កាប់ ទោះបីដឹងថា ដីនេះត្រូវបែងចែកអោយប្រជាជនវិញក៏ដោយ ។ សំអាងទៅលើមាត្រា២០០-២០១-២០២ នៃច្បាប់ ភូមិបាលសុំលុបបណ្ណ័សំគាល់សិទ្ធិលេខ$G_2$-០១១០ របស់លោក វ៉ង សារិន ចោលជាអសារបង់ ហើយលោក វ៉ង សារិន គួរតែប្តឹងទាមទារប្រាក់ពីលោកជុំ សៀង និង ឯក សំអួន តាមច្បាប់ ។

តាមសាលដីការដ្ឋប្បវេណីស្ថាពររបស់តុលាការកំពូល លេខ១៣៩ ចុះថ្ងៃ ទី១២ ខែសីហា ឆ្នាំ១៩៩៩ បានសំរេចសេចក្តីដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣៤៨ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៨ របស់លោកញ៉ឹក សំអាត តំណាងអោយអ្នកស្រី យឹម វ៉ាន់ ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹង គតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៩៤៨ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ដោយកែតម្រូវចំណុចទី៤ នៃសាលក្រមរដ្ឋប្បវេណី

លេខ ៣៩ "រ" របស់តុលាការខេត្តកណ្ដាល ស្ដីពីពន្ធ សមាមាត្រពី "១៩.២០០ដុល្លាអាមេរិក "មក "១៩.២០០រ" វិញ ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០រៀល ដែលអ្នកស្រី ឃឹម វ៉ាន់ បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្លឹង ចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប ១៩.០០០រៀល ។ បង្គាប់ឱ្យអ្នកស្រី ឃឹម វ៉ាន់ បង់ពន្ធសមាមាត្រ ៩៥.០០០រៀល ។

៤-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ ។

បានឃើញដីកាតំកល់រឿងទុកមិនចាត់ការលេខ៥០ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០០ របស់តុលាការខេត្តកណ្ដាល ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-តំកល់សំណុំរឿងរដ្ឋប្បវេណីលេខ ៤២២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩ ទុកមិនចាត់ការ ។

២-បង្គាប់ឱ្យចំណាយរឿងនេះចេញពីបញ្ជី ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៥៩ ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០០ របស់លោក កៅ ប៊ុនហុង ប្ដឹងមិនសុខចិត្ត នឹងដីកាតំកល់រឿងទុកមិនចាត់ការ លេខ៥០ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០០ របស់តុលាការខេត្តកណ្ដាល ត្រង់ ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៣"ង" ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែល មានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-៨-២០០០ របស់ឈ្មោះកៅ ប៊ុនហុង ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយ នឹងគតិច្បាប់ ។

២-តម្កល់ដីកាសំរេចតម្កល់រឿងទុកឥតចាត់ការលេខ៥០ចុះថ្ងៃទី០៧-៦-២០០០ របស់តុលាការ ខេត្តកណ្ដាល ទុកជាបានការ ។

៣-សំរេចកាត់យកប្រាក់ប្រដាប់ក្ដីនៅជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលឈ្មោះ វង សារិន បានបង់ទុករួចជាស្រេច គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្លឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រ ចំណាយលើការប្រគល់ដីកាកោះ៥០០០រៀល និងលើអាជ្ញាធរតុលាការ ៥០០០រៀល ។ កាលបើសាលដីកានេះ ចូលជាស្ថាពរហើយ បង្គាប់អោយឈ្មោះ កៅ ប៊ុនហុង សងប្រាក់ ១៣.០០០រៀលនេះ ទៅឈ្មោះ វង សារិន វិញ ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះ វង សារិន កំបាំងមុខឈ្មោះ កៅ ប៊ុនហុង ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៨២ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៣ របស់លោក កៅ ប៊ុនហុង ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ ៦៣"ង" ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៤២ "ង" ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០២-៧-២០០៣ របស់ឈ្មោះ កៅ ប៊ុនហុង ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយ នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ៦៣ "ង" ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទ កំបាំងមុខចុងចម្លើយ តែចាត់ទុកចំពោះមុខ ។

- បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៧២ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ របស់លោក គង់ ចំរើន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៤២ "ង" ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តី សំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ របស់លោក កៅ ប៊ុនហុង ។

បានឃើញសារណាតប ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ របស់លោក វង សារិន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: រឿងនេះ ចូលជាស្ថាពរហើយ ។ សាលដីការបស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះ គង់ ចំរើន នាពេលជំនុំជំរះបានឆ្លើយថា : បានជាខ្លួនប្តឹងសាទុក្ខពីសាលដីការបស់ សាលាឧទ្ធរណ៍មកពីដីនេះ ជាដីអាជ្ញាធរ ខេត្តកណ្តាល ។ ដីនេះប្រជាជនចូលនៅមិនមែនអនាធិបតេយ្យទេ គឺអាជ្ញាធរ បានចែកឱ្យ ។ ដីនៅក្នុងជំនាន់រដ្ឋកម្ពុជា អាជ្ញាធរអាចលប់បាន ។ ខ្លួនប្តឹងនេះ គឺជាផលប្រយោជន៍របស់ខេត្ត ប្រជាជន គ្មានជាប់សាច់ញាតិនឹងខេត្តទេ ។ ការលប់បណ្ណ័កម្មសិទ្ធិរបស់វង សារិន គឺត្រឹមត្រូវហើយ ដែលស្ថិតក្នុងច្បាប់រដ្ឋ កម្ពុជា បណ្ណ័កម្មសិទ្ធិនេះធ្វើនៅឆ្នាំ១៩៩២ ក្នុងរដ្ឋកម្ពុជា ។

បានស្តាប់អំណានរបស់ក្រឡាបញ្ជីអានសារណារបស់លោក វង សារិន នាពេលជំនុំជំរះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសែម ចិន្តា ជាមេធាវីការពារឱ្យចុងចម្លើយ បានលើកឡើងថា : នៅក្នុងរដ្ឋធម្មនុញ្ញក្តី ក្នុងអនុក្រឹត្យក្តី គឺគ្រាន់តែបើកសិទ្ធិឱ្យតវ៉ាទេ មិនឱ្យគាត់លប់ចោលទេ ។ បណ្ណ័កម្មសិទ្ធិកូនក្តីខ្លួនបាទចេញមុន អនុក្រឹត្យចេញក្រោយ ដូច្នេះមានតែតុលាការទេ ជាអ្នកសំរេច ហើយកន្លងមកក៏មានសាលដីការួចហើយដែរ ។ សំណូមពរ សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយតំណាងដើមចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីចុងចំលើយ .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៧២ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ របស់លោក គង់ ចំរើន ធ្វើឡើង ក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា រឿងក្តីលើដីទំនាស់នេះ ត្រូវបានតុលាការកំពូលសំរេចជាស្ថាពរ តាមសាលដីការដ្ឋប្បវេណីលេខ១៣៩ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ រួចហើយ ហើយបណ្ណ័សំគាល់សិទ្ធិលើដីទំនាស់លេខ$G_2$-០១១០ ចុះថ្ងៃទី០៨-០១-១៩៩២ ក៏ត្រូវបានតុលាការទទួលស្គាល់ក្នុងសាលដីកាស្ថាពររបស់តុលាការកំពូលខាងលើនេះដែរ ដូច្នេះ តុលាការកំពូល ពុំមានសមត្ថកិច្ចលើកយកប័ណ្ណសំគាល់សិទ្ធិដដែលនេះមកសំរេចសេចក្តីជាថ្មីទៀតទេ ។

- យល់ឃើញថា ការដែលដើមចោទលើកឡើងនៅពេលសវនាការនេះថា : ប័ណ្ណសំគាល់សិទ្ធិលេខ $G_2$ -០១១០ ចុះថ្ងៃទី០៨-០១-១៩៩២ ត្រូវបានអាជ្ញាធរខេត្តកណ្តាលលប់ចោលហើយនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះ អាជ្ញាធរខេត្តពុំមានសមត្ថកិច្ចលប់ចោលនូវប័ណ្ណសំគាល់សិទ្ធិលើដីឯកជនរបស់ពលរដ្ឋ ហើយដកហូតយកដីទៅឱ្យអ្នកដទៃបានទេ ។

-យល់ឃើញថា ចុងចម្លើយបានទទួលដីកាកោះឱ្យមកចូលរួមនាសវនាការនេះហើយ ប៉ុន្តែពុំបានមកចូលរួម នាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៤២ "ង" ចុះថ្ងៃទី២០ខែតុលាឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ
## កំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៧២ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ របស់លោកគង់ ចំរើន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ១៤២"ង" ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុក ជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោក គង់ ចំរើន បានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០៛សំរាប់ជារង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៤ ។